ក្រសួងមុខងារសាធារណៈ

MINISTRY OF CIVIL SERVICE

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតក្រុមការងារអ្នកនាំពាក្យ

# នៃក្រសួងមុខងារសាធារណៈ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ៥៧១៥៦/២៣ មស.សលទ

## សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារអ្នកនាំពាក្យនៃក្រសួងមុខងារសាធារណៈ

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារអ្នកនាំពាក្យ នៃក្រសួងមុខងារសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **យក់ ប៊ុនណា** | រដ្ឋលេខាធិការប្រចាំការ | ប្រធាន |
| ២. ឯកឧត្តម **ទី ហុកនិត** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ហាស់ ប៊ុនថ្លុន** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមុខងារសាធារណៈ | សមាជិក |
| ៤. ឯកឧត្តម **ពេជ្រ វិជ្ជានន្ទី** | អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ | សមាជិក |
| ៥. ឯកឧត្តម **ឈុន សុជាតិ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | សមាជិក |
| ៦. លោក **ពេជ្រ និពន្ធ** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ៧. លោកស្រី **ដារ៉េត រ៉ូហ្សាលីន** | អនុពន្ធសារព័ត៌មាន | សមាជិក ។ |



ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**ប្រការ២ ._**

ក្រុមការងារអ្នកនាំពាក្យនៃក្រសួងមុខងារសាធារណៈ មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំគ្រប់គ្រងលើការផ្សព្វផ្សាយព័ត៌មានផ្លូវការរបស់ក្រសួងមុខងារសាធារណៈ
- ទំនាក់ទំនង និងឆ្លើយឆ្លងព័ត៌មានផ្លូវការជាមួយសាធារណជន និងបណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ ពាក់ព័ន្ធវិស័យមុខងារសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពរបស់រាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធវិស័យមុខងារសាធារណៈ
- ប្រមូលព័ត៌មាន និងឯកសារពាក់ព័ន្ធតាមគ្រប់មធ្យោបាយ ដើម្បីឆ្លើយបំភ្លឺជាមួយសាធារណជន និងបណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ
- រៀបចំសន្និសីទសារព័ត៌មាននានាជូនថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ
- រៀបចំសេចក្តីប្រកាសព័ត៌មានក្រោយកិច្ចប្រជុំ ឬព្រឹត្តិការណ៍ផ្សេងៗរបស់ក្រសួងមុខងារសាធារណៈ តាមការចាំបាច់
- ផ្តល់យោបល់ និងតម្រង់ទិសដល់ក្រុមការងារបណ្តាញទំនាក់ទំនងសង្គមនៃក្រសួងមុខងារសាធារណៈ ដើម្បីដោះស្រាយ និងឆ្លើយតបនឹងសម្រង់ព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ
- ទទួលភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាននានា អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកសាលាភូមិន្ទរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍៤កើតខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហ៊ុន_ម៉ានី**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា

  **"ដើម្បីជូនជ្រាប"**

- ដូចប្រការ៤

  **"ដើម្បីអនុវត្ត"**

- ឯកសារ កាលប្បវត្តិ